**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខ : ✓ មស.

# សារលិខិតជូនពរ

**សូមគោរពជូន**
**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា**

**សម្តេចវិបុលសេនាភក្តី ជាទីគោរពដ៏ខ្ពង់ខ្ពស់**

ក្នុងឱកាសចម្រើនជន្មាយុគម្រប់៧៧ឆ្នាំ ឈានចូល៧៨ឆ្នាំ របស់ **សម្តេចវិបុលសេនាភក្តី** នៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២២ នេះ យើងខ្ញុំជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ សូមប្រសិទ្ធពរជ័យ សិរីសួស្តី បវរមហាប្រសើរ ជូនចំពោះ **សម្តេចវិបុលសេនាភក្តី** សូមសមប្រកបដោយសុខភាពល្អបរិបូរណ៍ កាយពលមាំមួន បញ្ញាញាណវាងវៃ និងជន្មាយុយឺនយូរ។

ក្នុងឱកាសដ៏វិសេសវិសាលនេះផងដែរ យើងខ្ញុំទាំងអស់គ្នា សូមអនុញ្ញាតសម្តែងនូវគារវកិច្ចគោរពដឹងគុណដ៏ស្មោះចំពោះទឹកចិត្តស្នេហាជាតិដ៏ថ្លៃថ្លា និងសកម្មភាពដ៏ឧត្តុង្គឧត្តមរបស់ **សម្តេចវិបុលសេនាភក្តី** ក្នុងបេសកកម្មដឹកនាំស្ថាប័នព្រឹទ្ធសភា ដែលជាស្ថាប័ននីតិប្បញ្ញត្តិកំពូលរបស់ជាតិ សម្រេចបាននូវសមិទ្ធផលធំៗជាច្រើន រួមចំណែកយ៉ាងសំខាន់ដល់ការធានាបាននូវនីតិរដ្ឋ សន្តិភាព ស្ថិរភាពសង្គម និងការអភិវឌ្ឍរបស់ប្រទេសជាតិលើគ្រប់វិស័យ។

សាជាថ្មីម្តងទៀត យើងខ្ញុំទាំងអស់គ្នា សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក សូមប្រោសប្រទានជូន **សម្តេចវិបុលសេនាភក្តី និង លោកជំទាវ ព្រមទាំង បុត្រា បុត្រី ចៅប្រុស ចៅស្រី** មានសុខភាពល្អបរិបូរណ៍ និងទទួលបានពុទ្ធពរទាំង៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចវិបុលសេនាភក្តី ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅ និងខ្ពង់ខ្ពស់បំផុតពីយើងខ្ញុំទាំងអស់គ្នា៕

ថ្ងៃចន្ទ ១៤រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២២
**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

**ហ៊ឹម ឆុន**

ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh